ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

# កំណត់ហេតុ

## កិច្ចប្រជុំបច្ចេកទេស ស្តីពីការពិនិត្យរបាយការណ៍វាយតម្លៃដោយស្ម័គ្រចិត្ត លើការអនុវត្ត GCM ថ្នាក់ជាតិ ដើម្បីត្រៀមចូលរួមវេទិកាវាយតម្លៃ ការងារអភិបាលកិច្ចទេសន្តរប្រវេសន៍ជាតិ (IMRF)

ថ្ងៃពុធ ៨ប់មួយកើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.ពីរពាន់ប្រាំរយហុកសិបប្រាំ ត្រូវនឹងថ្ងៃទីដប់មួយ ខែឧសភា ឆ្នាំពីរពាន់ម្ភៃពីរ វេលាម៉ោង ប្រាំបី និងសាមសិប នាទីព្រឹក នៅសណ្ឋាគារភ្នំពេញ មានបើកកិច្ចប្រជុំបច្ចេកទេស ស្តីពីការពិនិត្យរបាយការណ៍វាយតម្លៃដោយស្ម័គ្រចិត្តលើការអនុវត្ត GCM ថ្នាក់ជាតិ ដើម្បីត្រៀមចូលរួមវេទិកាវាយតម្លៃការងារអភិបាលកិច្ចទេសន្តរប្រវេសន៍ជាតិ(IMRF) ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដោយមានការអញ្ជើញចូលរួមពី

១.ឯកឧត្តម ញឹក វណ្ណារ៉ា រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
២.ឯកឧត្តម ហ៊ូ វុឌ្ឍី រដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
៣.ឯកឧត្តម កែវ វិសិដ្ឋ អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
៤.លោកជំទាវ ជូ ពុទ្ធានី អនុរដ្ឋលេខាធិការក្រសួងផែនការ
៥.លោកជំទាវ សួស រដ្ឋាវី អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
៦.លោកស្រី គ្រីស្ទីន ផាកូ ប្រធានបេសកកម្ម អង្គការ IOM
៧.លោកជំទាវ ឧត្តមសេនីយ៍ឯក ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ
៨.ឯកឧត្តម ប៉ែន ពេជ្រសាលី អគ្គនាយក ក្រសួងយុត្តិធម៌
៩.នាយឧត្តមសេនីយ៍ យក់ សុខា អគ្គស្នងការរងនគរបាលជាតិ
១០.ឯកឧត្តម ឧត្តមសេនីយ៍ឯក អ៊ុក ហៃសីឡា អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍
១១.លោកជំទាវ ឧត្តមសេនីយ៍ឯក លឹម រស្មី អគ្គនាយករង នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម

ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង គ.ជ.ប.ជ តំណាងក្រសួងសុខាភិបាល តំណាងទីចាត់ការការងារព្រំដែន តំណាងនាយកដ្ឋានព្រំដែនទឹក ព្រំដែនគោក នៃអគ្គស្នងការដ្ឋាននគរបាលជាតិ តំណាងអង្គការ ILO តំណាងអង្គការ UNICEF តំណាងអង្គការ UNW-SAF និងមន្ត្រីបច្ចេកទេសពាក់ព័ន្ធមួយចំនួនទៀតផងដែរ សរុបចំនួន ៣៦ រូប ស្រី ១៣ រូប ។

ជាកិច្ចចាប់ផ្តើម នៃកិច្ចប្រជុំ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ អញ្ជើញមានប្រសាសន៍ស្វាគមន៍ចំពោះវត្តមានរបស់ ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ

អនុរដ្ឋលេខាធិការ ឯកឧត្តម លោកជំទាវ អគ្គនាយក អគ្គនាយករង លោក លោកស្រីប្រធាន អនុប្រធាននាយកដ្ឋាន តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ តំណាងអង្គការដៃគូមួយចំនួនទៀតផងដែរ ។

**លោកជំទាវ** ប្រធានអង្គប្រជុំបានមានប្រសាសន៍បញ្ជាក់ជូនអង្គប្រជុំថា **លោកជំទាវ** ត្រូវបាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំគណៈប្រតិភូកម្ពុជា ទៅចូលរួមកិច្ចប្រជុំនៅទីក្រុងញូវយ៉ក សហរដ្ឋអាម៉េរិក នាថ្ងៃទី១៧ ដល់ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ ខាងមុខនេះ នឹងមានកិច្ចប្រជុំ ដើម្បីការពាររបាយការណ៍វឌ្ឍនភាព នៃការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ (GCM) និងការអភិវឌ្ឍផែនការជាតិ ។ លោកជំទាវ មានប្រសាសន៍បញ្ជាក់ថា ប្រទេសកម្ពុជា ត្រូវបានគេចាត់បញ្ចូលជាប្រទេសជ័យលាភី នឹងត្រូវបានអញ្ជើញធ្វើការចែករំលែកបទពិសោធន៍ដល់ប្រទេសដទៃទៀតពាក់ព័ន្ធការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ ។ **លោកជំទាវ** មានប្រសាសន៍បន្តថា កម្ពុជាបានអនុវត្តការងារទៅតាមលំដាប់លំដោយ នៃការដាក់គោលដៅដើម្បីជំរុញល្បឿនក្នុងការអនុវត្ត ហើយនៅពេលនោះ គឺស្របពេលដែលពិភពលោកត្រូវបានរាំងស្ទះដោយសារជំងឺកូវីដ-១៩ និងបានរួមគ្នាដើម្បីធ្វើការទប់ស្កាត់ ក្នុងនោះប្រទេសកម្ពុជាក៏បានទទួលជោគជ័យផងដែរក្នុងការរួមចំណែកទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩ ផងដែរ ដែលយើងអាចធ្វើការជួបជុំគ្នាដើម្បីពិនិត្យ ពិភាក្សា ពិគ្រោះយោបល់ឡើងវិញ ។ **លោកជំទាវ** បានបញ្ជាក់បន្ថែមថា កិច្ចប្រជុំក្នុងថ្ងៃនេះ អ្វីដែលជាចំណុចសំខាន់ គឺជាចំណុចដែលយើងត្រូវយកទៅពិភាក្សានៅទីក្រុងញូវយ៉ក សហរដ្ឋអាម៉េរិក ដែលនឹងត្រូវចេញដំណើរ ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២២ ខាងមុខនេះ ដូច្នេះសូម ឯកឧត្តម លោកជំទាវ លោក លោកស្រី ជួយផ្តល់មតិយោបល់ចំពោះការអនុវត្តផែនការការងារសំខាន់ៗ ចំនួន ៣ គឺ៖ **ទី១.** រំលឹកសកម្មភាព នៃការអនុវត្ត GCM ដោយស្ម័គ្រចិត្ត ដែលកម្ពុជាបានអនុវត្តនៅក្នុងឆ្នាំ២០២១ មកដល់ពេលនេះគឺយើងត្រូវធ្វើការវិវត្តន៍ (Update) ថាតើយើងបានធ្វើអ្វីបន្ថែមទៀតដែលប្លែក និងថ្មី ។ **ទី២.** ពិនិត្យឡើងវិញចំពោះផែនការសកម្មភាពការងារសម្រាប់ការអនុវត្ត GCM ដែលយើងបានជ្រើសរើសគោលបំណង ៣៖ **គោលបំណងទី១.**ការប្រមូល និងប្រើប្រាស់ទិន្នន័យ ដែលអាចជឿជាក់បាន និងមានការបែងចែកតាមប្រភេទជាមូលដ្ឋាន ។ **គោលបំណងទី២.** ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងភាពជាដៃគូសកល ស្តីពីទេសន្តរប្រវេសន៍ប្រកបដោយ សុវត្ថិភាព រៀបរយ និងស្របច្បាប់ **គោលបំណងទី៣.**ការគ្រប់គ្រងព្រំដែនរួមគ្នា ដោយសុវត្ថិភាព និងស៊ីចង្វាក់គ្នា ។ ចំណុចសំខាន់ទាំង ៣ ខាងលើនេះដែលប្រទេសកម្ពុជាបានប្រកាន់យកនៅក្នុងកិច្ចខិតខំប្រឹងប្រែងអនុវត្ត ។ **ទី៣.** គឺពិនិត្យលើសេចក្តីព្រាងចំពោះការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងការអនុវត្ត GCM ។

សមាជិក សមាជិកា នៃអង្គប្រជុំបានធ្វើការពិភាក្សាបញ្ចេញមតិយោបល់ទៅតាមចំណុចនីមួយៗដែលបានដាក់ជូនក្នុងកម្មវិធី៖

ដាបឋម **លោកជំទាវ ប្រធានអង្គប្រជុំ** បានលើកជាយោបល់អំពីការធ្វើទេសន្តរប្រវេសន៍ទៅប្រទេសថៃ ពីព្រោះប្រទេសថៃ គឺជាប្រទេសដែលមានពលរដ្ឋខ្មែរចំណាកស្រុកទៅធ្វើការច្រើនជាងប្រទេសផ្សេងទៀត ប៉ុន្តែខាង UN គេឲ្យលើកជាទូទៅ តើយើងគួរធ្វើបែបណាបើប្រទេសផ្សេងមិនមានពលរដ្ឋខ្មែរទៅធ្វើការងារច្រើនដូចប្រទេសថៃ? សូមអង្គប្រជុំជួយផ្តល់ជាមតិយោបល់ ។ ក្នុងចំណុច ១(ក). ទំព័រ១.បានលើកឡើងអំពីប្រាក់ឈ្នួលរបស់ពលករកម្ពុជានៅក្នុងប្រទេសថៃ មានចំនួនច្រើនជាង ៥ដង បើប្រៀបធៀបចំនួនប្រាក់ឈ្នួលពលករនៅកម្ពុជា

(ឆ្នាំ២០១៦) តើមានព័ត៌មាន Update បន្ថែមទៀតអត់? ពីព្រោះបានកន្លងផុតរយៈពេល៦ឆ្នាំហើយ សូមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អាចផ្តល់ព័ត៌មានបានអត់ចំពោះបញ្ហានេះ តើប្រាក់ឈ្នួលពលករខ្មែរនៅប្រទេសមានចំនួនច្រើនបែបនឹងមែនអត់? ឬមួយមានអ្វីទាក់ទាញ ឬមានអ្វីខុសប្រក្រតីផ្សេងទៀត? **លោកជំទាវ** ប្រធានអង្គប្រជុំ បានលើកឡើងក្នុងទំព័រ៦ ឃ្លាទី២. ការចុះអនុស្សរណៈយោគយល់គ្នាទ្វេភាគី រវាងរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃព្រះរាជាណាចក្រថៃ ស្តីពីកិច្ចសហប្រតិបត្តិការឆ្លើយតបចំពោះការជួញដូរមនុស្ស និងការបញ្ជូន ព្រមទាំងការប្រើប្រាស់កម្លាំងដោយស្របច្បាប់ ។ **លោកជំទាវ** មានប្រសាសន៍សូមឲ្យមានការរំលេចក្រសួង ស្ថាប័ន ពាក់ព័ន្ធ MOU ឬ Agreement ឬ កិច្ចព្រមព្រៀង ឬ កិច្ចសហប្រតិបត្តិការនានាណាមួយ សូមបញ្ចូលទៅក្នុងរបាយការណ៍នេះផងដែរ ដូចជាក្រសួងការបរទេស ក្រសួងការងារ ក្រសួងសង្គមកិច្ច អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ខេត្តជាប់ព្រំដែន មិនថាតែប្រទេសថៃទេ គឺរវាងកម្ពុជា-វៀតណាម ម៉ាឡេស៊ី កូរ៉េ ជប៉ុន ជាដើម ។ ចំពោះកិច្ចការងារគ្រប់គ្រងព្រំដែន ក្រសួងការងារបានដាក់ចេញជាផែនការរួចហើយ ដូច្នេះសូមក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធសូមអនុវត្តកិច្ចការងារនេះតាមគោលនយោបាយជាតិដែលបានកំណត់ ដូចជាក្រសួងការពារជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ជាដើម ពីព្រោះយើងមានគោលដៅអនុវត្តការងាររួមគ្នា ប៉ុន្តែការអនុវត្តផ្សេងគ្នា ដូច្នេះយើងត្រូវរួមសហការគ្នា និងមានទំនាក់ទំនងល្អជាមួយគ្នា ។ **លោកជំទាវ** បានលើកយកបញ្ហាអត្រានុកូលដ្ឋានកុមារដែលកើតនៅក្នុងប្រទេសថៃ ឬបានធ្វើដំណើរទៅជាមួយឪពុកម្តាយដោយមិនទាន់មានអត្រានុកូលដ្ឋាន នេះគឺជាបញ្ហាមួយសំខាន់ផងដែរ ដែលយើងត្រូវដឹងអំពីទិន្នន័យឲ្យបានច្បាស់លាស់ យើងមិនអាចស្មានបានទេ ដើម្បីងាយស្រួលធ្វើផែនការ ត្រូវធ្វើអ្វីខ្លះ? នេះក៏ជាបញ្ហាព្រំដែនផងដែរដែលគេបានចោទសួរមកយើង បន្តិចទៀតបន្ទាប់ពីធ្វើអត្រានុកូលដ្ឋាននៅក្នុងប្រទេសរួច យើងនឹងបន្តធ្វើដល់កុមារទេសន្តរប្រវេសន៍នៅក្រៅប្រទេសទៀត ។ ឆ្លើយតបទៅនឹងការលើកឡើងរបស់ លោកជំទាវ អនុរដ្ឋលេខាធិការក្រសួងផែនការ ពាក់ព័ន្ធគោលនយោបាយជាតិ (២០១៦-២០៣០) ស្តីពី (ការគ្រប់គ្រងទេសន្តរប្រវេសន៍ និងនគរូបនីយកម្ម) ចំណុចនេះយើងគួរដាក់បញ្ចូល ពិតជាសំខាន់ណាស់ ពីព្រោះពលករដែលទៅធ្វើការនៅបរទេសនឹង ត្រឡប់មកវិញនៅថ្ងៃណាមួយ ទោះបីជាគាត់ទៅធ្វើការនៅក្រៅប្រទេសប៉ុន្មានឆ្នាំក៏ដោយ គេនឹងឲ្យគាត់ត្រឡប់មកវិញ គាត់នឹងមិនអាចធ្វើការងារបានទៀតទេ ដូច្នេះពេលគាត់ត្រឡប់មកវិញគាត់ត្រូវការទីតាំង ទីកន្លែងរស់នៅ យើងគួររំលេចអំពីគោលនយោបាយនេះផងដែរ ។ **លោកជំទាវ** មានប្រសាសន៍កែសម្រួលពាក្យ (ការប្តេជ្ញាចិត្ត) មកជំនួសពាក្យ (សច្ចាប្រណិធាន) ការប្តេជ្ញាចិត្តរបស់យើងត្រូវនិយាយឲ្យចំចំណុចដែលអាចធ្វើបាន ក្នុងការកែប្រែ ស្ថានភាពទេសន្តរប្រវេសន៍នៅកម្ពុជា ឲ្យមានភាពល្អប្រសើរ ចំណុចមួយទៀតនៅក្នុងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល គួរប្រើសញ្ញា(-) មួយប្រយោគ ឬ ប្រើលេខរៀង (១,២,៣...) ។

**លោកជំទាវ ងួ ពុទ្ធានី** អនុរដ្ឋលេខាធិការក្រសួងផែនការ មានប្រសាសន៍លើកឡើងអំពីចំណុច(ខ) ទំព័រ៤ ថា៖ កម្ពុជា បានកំណត់ចេញគោលនយោបាយអទិភាពនានាពាក់ព័ន្ធនឹងទេសន្តរប្រវេសន៍ ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤(២០១៨-២០២៣) និងកំណត់ចេញបញ្ហាប្រឈម និងវិធានការនានា ដើម្បីដោះស្រាយបញ្ហានេះនៅក្នុងយុទ្ធសាស្ត្រផែនការអភិវឌ្ឍជាតិ ២០១៩-២០២៣ រៀបចំដោយក្រសួងផែនការ ។ ផែនការនេះបានកំណត់ចេញ ស្តីពីការពង្រឹងការអនុវត្តច្បាប់ការទប់ស្កាត់លំហូរចូលទេសន្តរប្រវេសន៍ខុសច្បាប់ និងការធ្វើ

សមាហរណកម្មឡើងវិញរបស់ជនទេសន្តរប្រវេសន៍ត្រឡប់មកវិញតាមរយៈការទទួលស្គាល់ជំនាញ និងការអនុវត្តកម្មវិធីគាំពារសង្គមរបស់រាជរដ្ឋាភិបាលកម្ពុជា ។ **លោកជំទាវ** មានប្រសាសន៍បន្ថែមពាក់ព័ន្ធនិងគោលនយោបាយនានាទាក់ទងទៅនឹងទេសន្តរប្រវេសន៍ យើងមានគោលនយោបាយជាតិ (២០១៦-២០៣០) ក្នុងនោះមានចំណុចមួយបាននិយាយថា (ការគ្រប់គ្រងទេសន្តរប្រវេសន៍ និងនគរូបនីយកម្ម) តើចំណុចនេះយើងគួរដាក់បញ្ចូលដែរឬទេ បើដាក់បញ្ចូល លោកជំទាវ នឹងរៀបចំឯកសារជូន ។

**លោកស្រី វ៉ោធា** (ILO) លើកជាមតិយោបល់ ឯកភាពចំពោះប្រសាសន៍លើកឡើងរបស់ **លោកជំទាវ ជូ ប៊ុនអេង** ពាក់ព័ន្ធនឹងការផ្ដោតចំពោះពលករធ្វើការនៅប្រទេសថៃ គឺយើងលើកឡើងទូទៅចំពោះពលករខ្មែរនៅប្រទេសផ្សេងៗផងដែរ ដូចជាប្រទេសកូរ៉េ ជប៉ុន ។ ចំពោះរយៈពេលកន្លងមក នៃការឆ្លងរាលដាលជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលកម្ពុជាបានខិតខំបំពេញការងារ ក្នុងការជួយដោះស្រាយបញ្ហាពលករនៅក្រៅប្រទេស និងក្នុងប្រទេស ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ មួយទៀតគឺការបើកដំណើរការច្រកទ្វារព្រំដែនឡើងវិញជាមួយប្រទេសជិតខាង យើងនឹងដាក់បញ្ចូលសកម្មភាពការងារទៅក្នុងរបាយការណ៍នេះផងដែរ ។

**លោក ម៉ន ម៉េត** (ILO) បានលើកឡើងដើម្បីចូលរួមជាមតិយោបល់ថា ពាក់ព័ន្ធគោលនយោបាយទេសន្តរប្រវេសន៍ការងារ ឃើញថាក្រសួងការងារ បានដាក់ចេញក្នុង ឆ្នាំ២០១៤-២០១៨ នៅក្នុងឆ្នាំ២០១៩-២០២៣ ក្រសួងការងារបានធ្វើការដាក់បញ្ចូលបន្ថែមផងដែរនូវគោលនយោបាយចាស់បន្តទៀត ព្រមទាំងផែនការអភិវឌ្ឍន៍សកម្មភាពប្រចាំឆ្នាំ រួមទាំងដំណោះស្រាយវិវាទថៅកែ និងពលករ ក្រៅប្រព័ន្ធតុលាការដែលជាគោលការណ៍ណែនាំថ្មីផងដែរ ដែលមានប្រសិទ្ធភាពក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ សកម្មភាពការងារនេះយើងបានដាក់បញ្ចូលក្នុងរបាយការណ៍ជាភាសាអង់គ្លេសរួចហើយ ។ លោក បានមានមតិបន្តថា សម្រាប់កម្ពុជាយើងបានធ្វើការបកប្រែពីភាសាអង់គ្លេសមកជាភាសាជាតិ ដែលហៅថា ឯកច្ឆ័នភាពអាស៊ាន ឆ្នាំ២០១៧ បានអនុម័តចុះហត្ថលេខាដោយក្រសួងការងារ និងបានចុះហត្ថលេខាដោយប្រមុខរដ្ឋគ្រប់ប្រទេសអាស៊ានទាំង១០ ក្នុងឆ្នាំ២០១៧ ហើយក៏បានក្លាយជាឯកសារដែលបានការពារ និងលើកកម្ពស់សិទ្ធិពលករនៅក្នុងក្របខ័ណ្ឌអាស៊ាន ស្ដីពី តួនាទីរបស់ប្រទេសបញ្ជូន តួនាទីរបស់ប្រទេសទទួល និងការការពារសិទ្ធិរបស់ពលករ ដូច្នេះឯកសារនេះយើងបានដាក់បញ្ចូលរួចរាល់ហើយដែរ ។ ថ្មីៗនេះផងដែរ ឆ្នាំ២០២១ ដើមឆ្នាំ២០២២ គោលការណ៍ណែនាំអាស៊ាន ស្ដីពីការគាំទ្រក្នុងការធ្វើមាតុភូមិនិវត្តន៍ និងធ្វើសមាហរណកម្មពលករ ក៏បានបកប្រែជាភាសាជាតិ និងចុះហត្ថលេខាដោយក្រសួងការងារ យើងនឹងធ្វើការបោះពុម្ពផ្សាយឲ្យបានទូលំទូលាយនូវឯកសារនេះក្នុងពេលឆាប់ៗ ។ ផ្សេងពីនេះទៀតក្រសួងការងារ រួមទាំងសមាគមជ្រើសរើសពលករបានរៀបចំឲ្យមានដំណើរការថ្មី ដើម្បីពង្រឹងសមត្ថភាព ការយកចិត្តទុកដាក់ក្នុងការជ្រើសរើសពលករ បញ្ជូនទៅក្រសួងការបរទេស នេះគឺជាការយកចិត្តទុកដាក់ចំពោះពលករនៅក្នុងក្របខ័ណ្ឌ ទាំងនេះយើងបានដាក់បញ្ចូលផងដែរ ។ លោក បានបន្ថែមចំណុចមួយចំនួនទៅក្នុងកតិកាសញ្ញាពិភពលោក ទី១.យើងដាក់ឆ្នាំ២០២២-២០២៤ ឬ ២០២៣-២០២៤ ដាក់ក្រោមចំណង ទី២.គួរប្រើពាក្យ(សេចក្ដីផ្ដើម) ជំនួសពាក្យ(សេចក្ដីសង្ខេប) ទី៣.សូមស្នើបន្ថែមពាក្យ(សហជីព ជាមួយនឹងថៅកែ) ។ ឯកភាព ទៅនឹងប្រសាសន៍របស់ លោកជំទាវ ប្រធានអង្គប្រជុំ ពាក់ព័ន្ធការប្ដេជ្ញាចិត្ត ថារំលេចអំពីគោលនយោបាយជាតិ ផែនការណ៍យុទ្ធសាស្ត្រជាតិ ការគ្រប់គ្រងប្រព័ន្ធទិន្នន័យ និងអ្វីដែលពាក់ព័ន្ធជាមួយគោលបំណងទាំង៣ ដែលយើងបានជ្រើសរើស។

**លោកជំទាវ សួស រដ្ឋាវី** អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានប្រសាសន៍ក្នុងកិច្ចប្រជុំថា មូលហេតុដែលនាំឲ្យមានការលំហូរ នៃការធ្វើទេន្តរប្រវេសន៍ សូមបញ្ជាក់ថានៅមុនឆ្នាំ១៩៩៧ មានមូលហេតុធំៗចំនួន ៣ គឺ៖ ទី១. បញ្ហាសង្គ្រាម ទី២.បញ្ហាអស្ថិរភាពផ្នែកនយោបាយ និងប្រព័ន្ធការងារផ្នែកឧស្សាហកម្ម ទី៣.ក្រោយអនុវត្តជោគជោគជ័យនូវគោលនយោបាយឈ្នះៗ មូលហេតុ នៃការធ្វើទេសន្តរប្រវេសន៍ គឺការស្វែងរកឱកាសការងារដែលល្អជាងឱកាសការងារនៅក្នុងស្រុករបស់ខ្លួន ។ ឆ្លើយតបទៅនឹងប្រសាសន៍របស់ លោកជំទាវប្រធានអង្គប្រជុំបានលើកឡើងអំពីប្រាក់ឈ្នួលរបស់ពលករនៅក្នុងប្រទេសថៃ គឺទទួលបានពីចន្លោះ ២៤៨ ដុល្លារទៅ ២៦៦ ដុល្លារ សហរដ្ឋអាម៉េរិក ក្នុង ១ខែ (ឆ្នាំ២០១៨) ដោយសម្រាប់ឆ្នាំ២០២២នេះ មានការកើនឡើងប្រហែលត្រឹមចំនួន ៣០០ ដុល្លារសហរដ្ឋអាម៉េរិក ក្នុង ១ខែ ។ **លោកជំទាវ** សូមឲ្យធ្វើការកែសម្រួលតួលេខប្រាក់ឈ្នួលដែលពកលរខ្មែរទទួលបាននៅក្នុងប្រទេសថៃ ។ **លោកជំទាវ** មានប្រសាសន៍បញ្ជាក់ថា ចំនួនតួលេខចំនួនពលករខ្មែរនៅក្នុងប្រទេសថៃចំនួន ២,០០០,០០០ នាក់ គឺក្រសួងការងារសូមកែតម្រូវតួលេខមកត្រឹមចំនួន ១,២០០,០០០ នាក់ និងសូមធ្វើការកែសម្រួលពាក្យពេចន៍ ខ្លឹមសារមួយចំនួនជាភាសាខ្មែរ ព្រោះឯកសារនេះបកប្រែពីភាសាបរទេស គឺមានការខ្វះចន្លោះបន្តិចបន្តួច ។ ពាក់ព័ន្ធនឹងការចំណាយលើការធ្វើទេសន្តរប្រវេសន៍ស្របច្បាប់ទៅប្រទេសថៃអស់ចំនួន ជាង ៧០០ ដុល្លារ ប៉ុន្តែជាក់ស្តែងយោងតាមកិច្ចប្រជុំទ្វេភាគីរវាងកម្ពុជា-ថៃ ក្នុងឆ្នាំ ២០១៧ បានកំណត់តម្លៃក្នុងការធ្វើទេសន្តរប្រវេសន៍ស្របច្បាប់ អស់ត្រឹមតែចំនួន ៣៣៣.០៧ ដុល្លារ សូមក្រុមការងារជួយកែសម្រួលត្រង់ចំណុចនេះផង មួយទៀតពាក់ព័ន្ធនឹងបច្ចុប្បន្នភាពរបស់ក្រុមហ៊ុនជ្រើសរើសពលករទៅធ្វើការនៅក្រៅប្រទេសឯកជនគិតត្រឹមឆ្នាំ២០២១ នេះ មានចំនួន ១១៩ ក្រុមហ៊ុនដែលកំពុងដំណើរការ ចំពោះពាក់ព័ន្ធនឹងតួលេខពលករវិលត្រឡប់មកវិញក្នុងរយៈពេល២ឆ្នាំ អំឡុងពេលជំងឺកូវីដ-១៩ មានចំនួនជាង ២៧ម៉ឺន នាក់ នៅក្នុងឯកសាររបស់យើងដាក់ត្រឹមតែចំនួន ១៥ម៉ឺននាក់ ស្នើសុំកែតួលេខនេះផងដែរ ក្រុមការងារក្រសួងការងារនឹងផ្ញើជូនបន្ទាប់ពីកិច្ចប្រជុំបានបញ្ចប់ ។ ចំពោះយុទ្ធនាការបន្តសុពលភាពក្នុងការជួយផ្តល់ភាពស្របច្បាប់ជូនពលករខ្មែរនៅក្នុងប្រទេសថៃ យើងចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ នេះទៅរយៈពេល ៣ខែ ដោយសហការរវាងក្រសួងមហាផ្ទៃ ក្រសួងការបរទេស និងក្រសួងការងារ ។

**ឯកឧត្តម ហ៊ី ខុឡូរី** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានប្រសាសន៍ពាក់ព័ន្ធផែនការសកម្មភាពការងារក្នុងការគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍ របស់ក្រសួងការងារ ឯកឧត្តម បានលើកឡើងកាលពីកិច្ចប្រជុំថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២២ នៅសណ្ឋាគារកាំបូឌីយ៉ាណា ម្តងរួចមកហើយដើម្បីដាក់បញ្ចូលទៅក្នុង GCM ។ ចំពោះការគ្រប់គ្រងព្រំដែន ក្រសួងការងារ ក៏មានគោលនយោបាយក្នុងការគ្រប់គ្រងព្រំដែនផងដែរដែលយើងដាក់ចេញសម្រាប់អនុវត្ត និងមានសកម្មភាពការងារជាច្រើនទៀត ក្រុមការងារនឹងផ្ញើជូនតាមក្រោយបន្ទាប់ពីកិច្ចប្រជុំ ។ **ឯកឧត្តម** បានមានប្រសាសន៍ពាក់ព័ន្ធការប្រើប្រាស់ពាក្យ (កុមារទេសន្តរប្រវេសន៍ ឬកូនទេសន្តរប្រវេសន៍) តើយើងគួរប្រើប្រាស់ពាក្យពេចន៍យ៉ាងណាឲ្យបានត្រឹមត្រូវ ឬយ៉ាងណា? សូមអង្គប្រជុំ អង្គការ IOM, ILO ជួយពិនិត្យមើល នេះគ្រាន់តែជាមតិចូលរួមប៉ុណ្ណោះ ។

**លោកស្រី ឃុន សុនា** ប្រធានកម្មវិធី អង្គការ UN-Women បានលើកជាមតិយោបល់ក្នុងកិច្ចប្រជុំថា នៅក្នុងវិបត្តិ នៃការរីករាលដាល នៃជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលកម្ពុជា មិនត្រឹមតែជួយដោះស្រាយវិបត្តិកូវីដ និងជំនួយ

មនុស្សធម៌ទេ ប៉ុន្តែក្រសួងកិច្ចការនារីបានយកចិត្តទុកដាក់ចំពោះអំពើហិង្សាលើស្ត្រី និងស្ត្រីធ្វើចំណាកស្រុកផងដែរ ក្រសួងកិច្ចការនារី ក៏បានយកចិត្តទុកដាក់ចំពោះកិច្ចការគ្រប់គ្រងព្រំដែន ការទទួលពលករជាពិសេសពលករជាស្ត្រី ដែលធ្វើឲ្យស្ត្រីទទួលបានសិទ្ធិ និងសេវាគាំពារមួយចំនួន ដូច្នេះតាមរយៈការងារទាំងនេះ លោកស្រី បានស្នើសុំអង្គប្រជុំមេត្តាពិនិត្យ សម្រេចគួរដាក់បញ្ចូលទៅក្នុងរបាយការណ៍ផង ។ ត្រឡប់ទៅសំណួរទី១ លោកស្រីបានលើកឡើងថា គឺជាមោទនភាព ដែលកម្ពុជាបានបង្កើតឲ្យមានផែនការជាតិដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី ដែលមានការទាក់ទងជាមួយគ្នាដែលយើងគួររំលេចនៅក្នុងរបាយការណ៍នេះផងដែរ ។ លោកស្រី មានមតិបន្ថែមថា ពាក់ព័ន្ធនឹងការធ្វើទេសន្តរប្រវេសន៍ ការជួញដូរមនុស្ស ចំណាកស្រុកដើម្បីការងារ គឺយើងមានគោលនយោបាយជាតិសំខាន់ៗចំនួន ៣ ក្នុងនោះក៏មានផែនការជាតិដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រីផងដែរ ។ ចំពោះគោលនយោបាយជាតិសំខាន់ៗទាំង៣ បើយើងមិនបានរំលេច ឬលើកយកមកបញ្ជាក់ឲ្យបានច្បាស់ទេ គេនឹងយល់ច្រឡំគិតថាកម្ពុជាទើបតែនឹងបង្កើតឡើងថ្មី មួយទៀតពាក់ព័ន្ធនឹងការបង្កើតក្រុមការងារបច្ចេកទេស ដែលនៅក្រោមឆ័ត្ររបស់គណៈកម្មាធិការជាតិ គ.ជ.ប.ជ មានក្រុមការងារបច្ចេកទេសជំនាញទាំង៦ ទទួលការងារខុសៗគ្នា រួចមកហើយ តើយើងបង្កើតថ្មីបន្ថែមទៀត ឬយើងអនុវត្តទៅតាមក្រុមការងារដែលមានស្រាប់? លោកស្រី មានមតិឯកភាពប្រសាសន៍ លោកជំទាវ ប្រធានអង្គប្រជុំ ពាក់ព័ន្ធការប្តេជ្ញាចិត្ត គឺយើងលើកយកតែចំណុចណាដែលមាននៅក្នុងគោលបំណងទាំង៣ ដែលបានជ្រើសរើស ក្រុមការងារគួរតែរំលេចគោលនយោបាយជាតិដែលមានស្រាប់ ទាក់ទងទៅក្នុងផែនការដែលបានដាក់នៅក្នុង GCM ដូចជាការគ្រប់គ្រងប្រព័ន្ធទិន្នន័យ ពង្រឹងទិន្នន័យ កិច្ចសហប្រតិបត្តិការអន្តរក្រសួង ការគ្រប់គ្រងប្រព័ន្ធការងារនៅតាមព្រំដែន ការគ្រប់គ្រងពលកររវាងប្រទេសទទួល និងប្រទេសបញ្ជូន គួរដាក់នៅក្នុងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ។

**លោកជំទាវ ឧត្តមសេនីយ៍ឯក លឹម រស្មី** អគ្គនាយករង នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម មានមតិចូលរួមក្នុងកិច្ចប្រជុំពាក់ព័ន្ធព័ត៌មានការងារលិខិតឆ្លងដែនថា អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម បានជួយសម្រួលដល់ការលំបាករបស់ប្រជាពលរដ្ឋខ្មែរ ដែលកំពុងស្នាក់នៅធ្វើការនៅក្នុងប្រទេសថៃ ដូចជាបានចាត់បញ្ជូនមន្ត្រីជំនាញទៅពន្យាលិខិតឆ្លងដែន ពន្យាសុពលភាពលិខិតធ្វើដំណើរ ផ្តល់អត្តសញ្ញាណបណ្ណដល់ប្រជាពលរដ្ឋខ្មែរដោយសហការជាមួយភាគីថៃ ដើម្បីផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ។ ពីឆ្នាំ២០១៤ រហូតមកដល់បច្ចុប្បន្ន បានបោះពុម្ពលិខិតធ្វើដំណើរជូនពលករនៅបរទេសចំនួន ៦៤៤,៨៩៨ក្បាល បានផ្តល់ជូនដល់ពលករ ចំនួន ៦៤៤,៩៤៨ ក្បាល ។

**លោកស្រី ចាន់ កញ្ញា** (UNICEF) មានមតិចូលរួមក្នុងកិច្ចប្រជុំថា បានធ្វើរបាយការណ៍ជា Soft Copy រួចហើយពាក់ព័ន្ធនឹងកុមារ ជាពិសេសកុមារទេសន្តរប្រវេសន៍ ឬកុមារដែលរងផលប៉ះពាល់ ។ លោកស្រី នឹងបញ្ជូនឯកសារទៅក្រុមការងារឲ្យបានឆាប់រហ័សបន្ទាប់ពីកិច្ចប្រជុំ ។

**លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានប្រសាសន៍បូកសរុបលទ្ធផល និងបិទកិច្ចប្រជុំដោយលោកជំទាវបានលើកឡើងថា ព្រឹកនេះយើងបានធ្វើការពិភាក្សាលើប្រធានបទចំនួន ៣៖ ទី១.ការវាយតម្លៃដោយស្ម័គ្រចិត្តនូវការការអនុវត្តកតិកាសញ្ញាពិភពលោក ដែលយើងបាន Update ច្រើននូវព័ត៌មានថ្មីៗ ។ **លោកជំទាវ** បានស្នើដល់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ជួយផ្តល់ព័ត៌មាន ឬ

លទ្ធផលការងារថ្មីៗដែលបានអនុវត្តនៅក្នុងឆ្នាំ២០២០ ដល់ឆ្នាំ២០២២ ឬជាការកែសម្រួលនៅក្នុងឯកសារព្រាងនេះ ដើម្បីដាក់បញ្ចូលទៅក្នុងរបាយការណ៍ ។ ទី២.និយាយអំពីផែនការអនុវត្ត GCM ថ្នាក់ជាតិ ដែលផែនការនេះ យើងអាចចាត់ទុកជាផែនការមេបណ្ដោះអាសន្ន ពីព្រោះយើងមិនទាន់អាចអនុវត្តបានទេ យើងមិនទាន់ដឹងថាអ្នកណាធ្វើអីនៅឡើយទេ យើងនឹងជួបគ្នាបន្តទៀតដើម្បីកំណត់ឲ្យបានច្បាស់លាស់ថាតើក្រសួង ស្ថាប័នណាធ្វើអី ដឹកនាំការងារអី? ទី៣.ការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល យើងជាប្រទេសដែលមានពលកររច្រើន យើងត្រូវការពារពលកររបស់យើង ធ្វើយ៉ាងណាឲ្យពលករខ្មែរយើងទទួលបានសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់ ដូចយើងបានរំពឹងទុក គឺជួយសម្រាលបន្ទុកសម្រាប់ជាតិយើង ដូច្នេះ GCM ពិតជាមានផលប្រយោជន៍ដល់ប្រទេសជាតិយើង ហើយត្រូវខិតខំប្រឹងប្រែងធ្វើឲ្យបានសម្រេច ។ **លោកជំទាវ** មានប្រសាសន៍រំលឹកថា កាលពីឆ្នាំ២០១៣ យើងមានសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល ស្ដីពីការគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍ និងកម្លាំងពលកម្ម សម្រាប់ក្រសួង ស្ថាប័ននីមួយៗអនុវត្តប៉ុន្តែរហូតមកដល់ពេលនេះ នៅមិនទាន់មានក្រសួង ស្ថាប័នណាមួយរំលេច និងអនុវត្តបាននៅឡើយ បញ្ហានេះមិនមែនជាបន្ទុករបស់ក្រសួងការងារតែមួយទេ ចាប់តាំងពីពេលពលករចេញដំណើរ រហូតពលករត្រឡប់មកវិញ ។ **លោកជំទាវ** មានប្រសាសន៍សង្ឃឹមថាយើងនឹងអនុវត្តការងារនេះបានជោគជ័យ ក្នុងការជួយដល់ពលករខ្មែរយើងឲ្យទទួលបានសិទ្ធិ និងគុណប្រយោជន៍ស្របច្បាប់ ។

ចុងបញ្ចប់ នៃកិច្ចប្រជុំ **លោកជំទាវ ប្រធានអង្គប្រជុំ** មានប្រសាសន៍ថ្លែងអំណរគុណចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័ន តំណាងអង្គការដៃគូពាក់ព័ន្ធទាំងអស់ដែលបានចូលរួមក្នុងកិច្ចប្រជុំថ្ងៃនេះ ជួបតែសេចក្ដីសុខ ទទួលជោគជ័យគ្រប់ភារកិច្ច ចៀសផុតពីជំងឺទាំងឡាយ ។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង ដប់ពីរ ថ្ងៃត្រង់ ថ្ងៃខែឆ្នាំដដែល ដោយបរិយាកាសរីករាយ ។

ថ្ងៃសុក្រ ១៣កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២
**អ្នកធ្វើកំណត់ហេតុ**

វររសេនីយ៍ទោ. សៅ ស៊ីនួន

**គោរពជូន**
**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**
មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។
ថ្ងៃពុធ ៣ រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែឧសភា ឆ្នាំ២០២២
**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯក វេជ្ជ.ប៊ុណ្ណ សំខាន់

បានឃើញ
24/05/22